**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខៈ ០៣៤/១៦ សវណ.៨

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
# ស្តីពី
# ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៧

សាលារាជធានីភ្នំពេញ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧ ។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃនៅគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។អ្នកទទួលការត្រូវបានបែងចែកជា០៣ ប្រភេទៈ

-ប្រភេទទី១ៈអ្នកទទួលការសំណង់ទូទៅ(ការងារសំណង់អគារ និងការងារបេតុង.....)។ល។

-ប្រភេទទី២ៈអ្នកទទួលការ ការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវគ្រួសក្រហម.....)។ល។

-ប្រភេទទី៣ៈអ្នកទទួលការឯកទេស ( អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេស សម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ....)។ល។

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខាគ្រប់គ្រាន់ដូចមានបរិយាយ នៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗដែលបានស្នើសុំ យ៉ាងតិច០២ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនអ្នកទទួលការ និងវាយតំលៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ការអនុវត្តការងារទាន់ពេលវេលានិងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការ ជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក ។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការលក្ខណសម្បត្តិនឹងដាក់ជូនឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីដើម្បីពិនិត្យ និងសម្រេច ។ អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិតស៊ីគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះនឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះ ក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគ សាលារាជធានីភ្នំពេញ ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៧:០០ ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មី

ឡើងវិញដែរ ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគ ដោយឥតបង់ថ្លៃ ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណសាលារាជធានីភ្នំពេញ ឬអាចទាញយកពីក្នុងគេហទំព័ររបស់គ.ជ.អ.ប(www.ncdd.gov.kh) ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ចម្លងជូន**:
-លេខាធិការដ្ឋានគ.ជ.អ.ប
"ដើម្បីជូនជ្រាប "
-ឯកសារ កាលប្បវត្តិ

**ប៉ា សុជាតិវង្ស**